# ការបង្កើតសួនដំណាំ



## ចូលរួមជាមួយពួកយើងឥលូវនេះ!

តើអ្នកចូលចិត្តធ្វើសួនដែររឺទេ?
សួនដំណាំជាប្រភពធនធានដ៏ល្អមួយដែលប្រមូលផ្តុំទៅដោយអាហារូបត្ថម្ភ និង ការអប់រំ។
វាជួយឲ្យកុមារៗ និង សហគមន៍អាចធ្វើការរួមគ្នាជាមួយនឹងម្តាយឪពុករបស់ពួកគេបានផងដែរ។
ការបង្កើតសួននៅតាមសាលារៀន និង សហគមន៍អាចជាវីធីសាស្រ្តដ៏អស្ចារ្យមួយសម្រាប់អ្នកដែលចាប់ផ្តើមគិតគូរពីការថែទាំសុខភាពផ្លូវកាយ និង ផ្លូវចិត្ត តាមរយៈការបរិភាគ និង ការធ្វើហត្ថកម្ម។ ដូច្នេះ ហេតុអ្វីយើងមិនចាប់ផ្តើមការដាំដំណាំនៅតាមសាលារៀន និង សហគមន៍ពីពេលនេះទៅ?វាជាសកម្មភាពសប្បាយៗដែលយើងអាចរួមគ្នាដាំដំណាំ ហើយ មើលឃើញពីការលូតលាស់ និង ទិន្នផលរបស់វាថែមទៀតផង។

**ដាំ ចម្អិន និង ញ៉ាំអាហារផ្ទាល់ខ្លួន!**

# ការបង្កើតសួនដំណាំ



## សម្រាប់ព័ត៌មានបន្ថែម

សូមចូលទៅកាន់គេហទំព័ររបស់យើង:

**www.foodplantsolutions.org**

សម្រាប់ចម្ងល់ រឺ ការបញ្ចេញមតិ សូមផ្ញើអ៊ីម៉ែលមកកាន់:

**info.foodplantsolutions.org**

សម្ភារៈជំនួយមួយចំនួនអាចស្វែងរកបាននៅក្រោមលីងនេះ :

**www.fao.org/docrep/009/a0218e/A0218E01.**

FOOD PLANT SOLUTIONS
ROTARIAN ACTION GROUP

**"Food Plant Solutions" ត្រូវបានទទួលស្គាល់ជា Rotarian Action Group និង ដំណើរការដោយយោងតាមគោលនយោបាយរបស់ Rotary International Policy ប៉ុន្តែយើងមិនមែនជាភ្នាក់ងារ រឺ ត្រូវបានគ្រប់គ្រងដោយ Rotary International.**

# ការបង្កើតសួនដំណាំ



## នៅក្នុងសាលារៀន និង សហគមន៍

**ទទួលយកបទពិសោធន៍ និង អត្ថប្រយោជន៍កាន់តែប្រសើរពីអាហារូបត្ថម្ភ និង ការបង្កើនកម្រិតថាមពលដល់រាងកាយ តាមរយៈការដាំដំណាំ និង ទទួលទានផលិតផលដែលអ្នកបានដាំដុះដោយខ្លួនឯងផ្ទាល់។**

FOOD PLANT SOLUTIONS
ROTARIAN ACTION GROUP

# គិចនិកក្នុងការចាប់ផ្ដើមដាំដំណាំនៅតាមសាលារៀន រឺ សហគមន៍



## រៀបចំគម្រោង

- **កំណត់មាត្រដ្ឋាន** រឺ ទំហំនៃសួនរបស់អ្នក
- **ចាប់ផ្ដើមទ្រង់ទ្រាយតូច**-ដោយដាំគ្រាប់ពូជ រឺ រុក្ខជាតិក្នុងផើងនៅថ្នាក់រៀន និង តាមដានពីការលូតលាស់របស់វា។
- **ពង្រីកឲ្យធំ- ស្វែងរកទីតាំងធំដែលអាចបង្កើតសួនដំណាំតែម្ដង។**
- **ស្វែងរកជំនួយ**-និយាយជាមួយគ្រូ នាយកសាលា រឺ ប្រធានសហគមន៍អំពីគម្រោងបង្កើតសួនរបស់អ្នក។ មនុស្សមួយចំនួនអាចនឹងចាប់អារម្មណ៍ចូលរួមជាមួយអ្នក ដោយពួកគេអាចផ្ដល់ដីជាទីតាំង រឺ ជំនួយផ្សេងៗ។
- **ថតរូបភាពឲ្យបានច្រើន**-សម្រាប់ទុកជាកំណត់ត្រា អនុស្សាវរីយ៍ និង ភស្តុតាងនៃសកម្មភាពដែលមិត្តរបស់អ្នកបានចូលរួមជាមួយ។

## ការស្រាវជ្រាវ

**ស្វែងរកព័ត៌មានមួយចំនួនទៀតពីការបង្កើតសួន។ ពាក្យគន្លឹះរួមមាន៖**

- អាហារូបត្ថម្ភ
- រុក្ខជាតិក្នុងតំបន់ដែលអាចបរិភោគបាន
- ការរក្សាស្ថេរភាព
- ដំណាំចម្រុះ
- សារធាតុបំប៉ន



## ជំហាននៃការចាប់ផ្ដើម

**ទីតាំង** - ត្រូវប្រាកដថាអ្នកមានទីតាំងធំទូលាយដែលមិត្តរបស់អ្នកងាយស្រួលធ្វើការរួមគ្នា។

## ការបង្កើតសួន

- **សម្អាតទីធ្លា**- ដើម្បីការពារសុវត្ថិភាពរបស់ពួកគេ ត្រូវប្រាកដថាមិត្តរបស់អ្នកទទួលបានការបណ្ដុះបណ្ដាលពីការប្រើប្រាស់សម្ភារៈដែលនឹងត្រូវកាប់គាស់ដី ។
- **បែងចែកមាត្រដ្ឋានសួន** - ប្រើខ្សែសម្គាល់ពីការកាត់ចំណែកទំហំដីសម្រាប់ការដាំដុះតាមក្រុមដំណាំនីមួយៗរួមមានដូចជា:
  - **បន្លែ**
  - **ផ្លែឈើ**
- វាស់វែងពីកម្ពស់ និង ទទឹង នៃដំណាំនីមួយៗដែលអ្នកចង់បាន។ បើអាចអ្នកគួរស្វែងរកដំបូន្មានល្អៗពីអ្នកជំនាញ។
- តើអ្នត្រូវការជីកំប៉ុសសម្រាប់ការដាំដុះតាមដំណាំធម្មជាតិដែររឺទេ?

FOOD PLANT SOLUTIONS
ROTARIAN ACTION GROUP



## ការដាំដុះ

- អ្នកប្រហែលជាត្រូវការជំនួយបរិច្ចាគនូវគ្រាប់ពូជ រឺ រុក្ខជាតិតូចៗ
- តើអ្នកត្រូវស្រោចដំណាំប៉ុន្មានដងជាប្រចាំ?
- តើដំណាំទាំងអស់សុទ្ធតែត្រូវការទឹកក្នុងបរិមាណដូចគ្នាមែនរឺទេ?

## ការថែទាំ

តើដំណាំទាំងអស់សុទ្ធតែត្រូវថែទាំដោយយកចិត្តទុកដាក់មែនដែររឺទេ? ថតរូបឲ្យបានច្រើន និង ត្រូវប្រាកដថាយើងអាចតាមដានពីការលូតលាស់របស់ដំណាំខុសគ្នាៗនៅក្នុងសួន។

## ការប្រមូលផល

ទីបំផុត អ្នកអាចរីករាយនឹងការទទួលទានរបស់ដែលអ្នកខំដាំដោយផ្ទាល់ដៃ។ គួររករិធីសាស្ត្រចម្អិនម្ហូបដែលជាចំណង់ចំណូលចិត្តរៀងៗខ្លួន។ សូមរីករាយទាំងអស់គ្នា!

## គិតចង់ដាំអ្វី?

តើឥលូវនេះអ្នកត្រូវដាំដំណាំអ្វីខ្លះទៀត? ដំណាំនោះជាអ្វីដែរ?